នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 19-Apr-2011, 15:21
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា
# អំពីបញ្ហាច្បាប់ដែលខ្លួនមានបំណងចង់លើកនៅពេលសវនាការបឋម

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម ធូ មណី

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ជនជាប់ចោទ:**
នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម

លោក Michael G.KARNAVAS
លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS QC
លោក ស សូវ៉ាន
លោក Jacques VERGÈS
លោក Phillipe GRECIANO

## ១. សេចក្តីជូនដំណឹង

១. ដោយអនុលោមតាមវិធាន ៨០.៣.គ នៃវិធានផ្ទៃក្នុង និង "ដីកាបង្គាប់ឲ្យដាក់សម្ភារៈដើម្បីរៀបចំសវនាការ" របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១[1] សហព្រះរាជអាជ្ញាសូមធ្វើការបញ្ជាក់ជូនអង្គជំនុំជម្រះសាលាដំបូងថា សហព្រះរាជអាជ្ញាមានបំណងចង់លើកពីបញ្ហាច្បាប់មួយចំនួននៅពេលសវនាការបឋម ដូចតទៅ៖

(១) *សេចក្តីសន្និដ្ឋានបើកការចោទប្រកាន់:* រយៈពេល និង ទម្រង់ *(វិធាន៨៩ស្ទួន១)*

(២) *អង្គហេតុដែលមិនជំទាស់តវ៉ា៖* អនុភាពនៃការបង្ហាញសវនាការ *(វិធាន៨០.៣.ង)*

(៣) *ភស្តុតាងឯកសារ៖* ការជំទាស់, វិធីសាស្ត្រនៃការទទួលយក, កំណត់ហេតុស្តាប់ចម្លើយសាក្សី *(វិធាន៨០.៣.ឃ និង ៨៧)*

(៤) *ការចូលខ្លួនរបស់ជនជាប់ចោទនៅពេលសវនាការ៖ (វិធាន៨១)*

(៥) *សក្ខីកម្មរបស់ជនជាប់ចោទ៖* លេខរៀង, រយៈពេល, របៀបសួរចម្លើយ និងការបែងចែកពេលវេលា *(វិធាន៨៩ស្ទួន២ និង ៩០)*

(៦) *សក្ខីកម្មរបស់សាក្សី៖* ចំនួន, លេខរៀង, រយៈពេល, របៀបស្តាប់ចម្លើយ និងការបែងចែកពេលវេលា *(វិធាន ៨៤ និង ៩១)*

(៧) *សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី៖* លេខរៀង, រយៈពេល, របៀបស្តាប់ចម្លើយ និងការបែងចែកពេលវេលា *(វិធាន ៩១)*

(៨) *ការជំទាស់៖* ប្រភេទ និង របៀប

(៩) *ការជូនដំណឹងពីសំណើសុំធ្វើការកំណត់បទចោទសាជាថ្មី នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ រួមមាន៖*

(ក) ជម្លោះប្រដាប់អាវុធមិនតម្រូវឲ្យមានការបង្ហាញសក្ខីកម្មពីអំពើឧក្រិដ្ឋណាមួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ

(ខ) ការរំលោភសេពសន្ថវៈជាអំពើឧក្រិដ្ឋមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

(គ) ការប្រព្រឹត្តិឧក្រិដ្ឋកម្មនានាតាមទម្រង់ទីបីនៃសហកម្មឧក្រិដ្ឋកម្មរួម*(វិធាន ៩៨)*

[1] ឯកសារលេខ E9 "ដីកាបង្គាប់ឲ្យដាក់សម្ភារៈដើម្បីរៀបចំសវនាការ" របស់អង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី១៧ មករា ២០១១, កថាខណ្ឌទី១៥

២. សហព្រះរាជអាជ្ញា ក៏សូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងផងដែរថា សូមឱ្យផ្តល់នូវកាលានុវត្តភាពពេញលេញដល់សហព្រះរាជអាជ្ញា ដើម្បីឆ្លើយតបទៅនឹងបញ្ហាផ្នែកច្បាប់ណាមួយក៏ដោយ ដែលបានលើកឡើងដោយភាគីដទៃទៀត នៅពេលសវនាការបឋម៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |